# សៀវភៅណែនាំ

# ស្តីពី

# ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាស

# ដេញថ្លៃគម្រោង ក្រុង ស្រុក ខណ្ឌ

# របស់ លេខាធិការដ្ឋាន គ.ជ.អ.ប

## 1. លក្ខណៈទូទៅ

ប្រព័ន្ធគ្រប់គ្រង់ការប្រកាសដេញថ្លៃក្រុង ស្រុក ខណ្ឌរបស់ គ.ជ.អ.ប គឺជាប្រព័ន្ធគ្រប់គ្រងការប្រកាស់ដេញថ្លៃដែលអនុញ្ញាតឲ្យបុគ្គលិកតាមបណ្ដាលខេត្តក្រុងដែលមានតួនាទីពាក់ព័ន្ធ អាចមានសិទ្ធនិងលទ្ធភាពធ្វើការប្រកាសពីគម្រោងអភិវឌ្ឍន៍របស់ក្រុង ស្រុក ខណ្ឌតាមគេហទំព័រ។ លើសពីនេះទៅទៀតប្រព័ន្ធគ្រប់គ្រងការប្រកាសដេញថ្លៃរបស់ក្រុង ស្រុក ខណ្ឌនេះ អាចអនុញ្ញាតអោយអ្នកធ្វើការដេញថ្លៃអាចស្វែងរកទិន្នន័យរបស់គម្រោងយ៉ាងឆាប់ហ័ស និងងាយស្រួល។ ប្រព័ន្ធគ្រប់គ្រងនេះ បានបែងចែកប្រភេទអ្នកប្រើប្រាស់ជាពីដូចខាងក្រោម

| បុព្វសិទ្ធ | ពិពណ៌នាតួនាទី |
|---|---|
| អ្នកគ្រប់គ្រងប្រព័ន្ធ | មានសិទ្ធក្នុងការបង្កើតគណនីអ្នកប្រើប្រាស់ និងកំណត់សិទ្ធ ព្រមទាំងអ្នកអាចធ្វើការផ្សព្វផ្សាយ និងបដិសេធប្រកាសបានផងដែរ។ |
| អ្នកបង្កើតប្រកាស | សំដៅលើអ្នកបង្កើតប្រកាសនៅតាមក្រុង ស្រុក ខណ្ឌនីមួយៗ ដែលទទួលបន្ទុកគ្រប់គ្រងលើការបញ្ចូលទិន្នន័យលើការដេញថ្លៃ អ្នកបង្កើតប្រកាសម្នាក់អាចមានសិទ្ធធ្វើការបង្កើត និងបដិសេធ ទៅលើក្រុង ស្រុក ខណ្ឌនីមួយដែលបានកំណត់អោយតែប៉ុណ្ណោះ។ |

ដើម្បីអាចប្រើប្រាស់ប្រព័ន្ធនេះបាន អនុកម្មវិធី និងរាជធានី ខេត្ត ទាំងអស់ ត្រូវរៀបចំការតែងតាំងអ្នកទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធដេញថ្លៃនេះ ហើយបញ្ជូនឈ្មោះមកលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីស្នើរបង្កើតគណនីអ្នកប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាសដេញថ្លៃក្រុង ស្រុក ខណ្ឌ។ប្រព័ន្ធទិន្នន័យនេះមានផ្ទុកទៅដោយព័ត៌មានសំខាន់ជាច្រើនអំពីការដេញក្នុងការគម្រោងអភិវឌ្ឍន៍ ក្រុង ស្រុក ខណ្ឌះ ដូច្នេះចាំបាច់តម្រូវឲ្យអ្នកបង្កើតប្រកាសម្នាក់ៗមានទំនួលខុសត្រូវ និងមានភាពប្រុងប្រយ័ត្នខ្ពស់។

## 2. វិធីសាស្រ្តចូលទៅគ្រប់គ្រងប្រព័ន្ធ

ការគ្រប់គ្រងប្រព័ន្ធ ដេញថ្លៃគម្រោងរបស់ក្រុង ស្រុកតាមរយៈប្រព័ន្ធអេឡិចត្រូនិចមានលក្ខណៈងាយស្រួលចំនេញពេលវេលា និងជួយសម្រួលការងារជាច្រើន សម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធគ្រប់លំដាប់ថ្នាក់។ ប៉ុន្តែ ដើម្បីទទួលបាននូវប្រសិទភាព និងគោលបំនងនៃការបង្កើតប្រព័ន្ធនេះ គឺទាមទារអោយមាន ការយកចិត្តទុកដាក់ និងមានភាពប្រុងប្រយ័ត្នខ្ពស់ ពីព្រោះរាល់ប្រកាសដែលបានធ្វើការផ្សព្វផ្សាយជាសាធារណៈ ឬបដិសេធរួចហើយ មិនអាចកែប្រែ ឬលុបចោលបាននោះទេ។ដើម្បីប្រកាសបានដំបូងយើងត្រូវចូលទៅកាន់ ទំព័រគ្រប់គ្រងប្រកាសដោយចុចគ្រប់គ្រង។




បន្ទាប់មកយើង នឹងឃើញទំព័រមួយផ្សេងទៀត ដែលតម្រូវឲ្យបញ្ចូល **ឈ្មោះក្នុងប្រព័ន្ធ និងលេខសំងាត់** សម្រាប់ចូលទៅ ធ្វើការបង្កើតប្រកាស ឬបដិសេធ ដែលមានរូបភាពដូចខាងក្រោម៖




បន្ទាប់ពីធ្វើការចូលទៅកាន់គេហទំព័រគ្រប់គ្រងបានជាស្ថានពរហើយ យើងនឹងឃើញមាន ទិន្នន័យសង្ខេបអំពីអ្នកប្រើប្រាស់ប្រព័ន្ធ គម្រោងដេញថ្លៃ និងប៊ូតុងមួយចំនួនដែលតួនាទីសំខាន់ៗខុសៗគ្នា។




ឈ្មោះប៊ូតុង និងមុខងាររបស់វា

- **ទំព័រដើម** មុខងាររិលត្រឡប់ទៅកាន់ទំព័រដើមវិញ( ទំព័រដែលយើងឃើញនៅពេលចូលប្រើប្រាស់ )
- **បង្កើតប្រកាស** មុខងារសម្រាប់បង្កើតប្រកាស់ថ្មី។
- **បញ្ជីប្រកាស** មុខងារសម្រាប់ទៅទំព័រត្រួតពិនិត្យមើលរាល់ប្រកាស និងអាចធ្វើការបដិសេធបាន។
- **ជំនួយ** មុខងារ ដើម្បីទាញយកឯកសារជំនួយក្នុងការប្រើប្រាស់ប្រព័ន្ធ។

## 3. ការបង្កើតប្រកាស

ដើម្បីធ្វើការបង្កើតប្រកាសបានយើងត្រូវបំពេញទីវងចំនួនពី។ទំរងទីមួយ គឺស្ដីអំពីស្រុក កន្លែងដែលអាចទទួលឯកសារបាន និងថ្ងៃបរិច្ឆេទផ្សព្វផ្សាយ និងទទួលសំណើរដេញថ្លៃជាដើម។ទំរងទីពីរ គឺស្ដីអំពីឈ្មោះគម្រោង និងទីតាំងគម្រោង។

### 3.1. ការបញ្ចូលទិន្នន័យលើទំរង់ទី១



ទិន្នន័យនិងលក្ខខ័ណ ដែលត្រូវបញ្ចូលនៅក្នុងទំរងនីមួយមានដូចជា៖

- **ក្រុង/ស្រុក/ខណ្ឌ** ណាមួយនៃគម្រោងដែលមានក្នុងក្នុងខេត្តឬក្រុងដែលបានកំណត់រួចជាស្រេច។
- **ទីកន្លែងលក់ឯកសារពិគ្រោះថ្លៃ** បំពេញទៅតាមប្រកាស ឧ.ស្ថិតក្នុងបរិវេណក្រសួងមហាផ្ទៃ (អគារ T)មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- **ទីកន្លែងនៃការបើកសំណើរពិគ្រោះថ្លៃ** បំពេញទៅតាមប្រកាស ឧ.ស្ថិតក្នុងបរិវេណក្រសួងមហាផ្ទៃ (អគារ T)មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- **កាលបរិច្ឆេទដាក់លក់ឯកសារពិគ្រោះថ្លៃ** តាមនីតិវិធីកាលបរិច្ឆេទប្រជុំបើកសំណើរដេញថ្លៃ ត្រូវតែប្រព្រឹត្តទៅតាមច្បាប់
- **កាលបរិច្ឆេទឈប់លក់ឯកសារពិគ្រោះថ្លៃ និងកាលបរិច្ឆេទបើកសំណើរពិគ្រោះថ្លៃ** ពេលវេលាដែលបានកំណត់ត្រូវតែធំជាង តម្លៃនៃការ កាលបរិច្ឆេទដាក់លក់ឯកសារពិគ្រោះថ្លៃ

ក្រោយពីបានបញ្ចូលទិន្នន័យទៅក្នុងទំរង់ទី១រួចរាល់ ដើម្បីរក្សាទុកទិន្នន័យទាំងនោះទៅក្នុងប្រព័ន្ធ លោកអ្នកត្រូវចុចប៊ូតុង រក្សាទុក។

**ចំណាំ៖** សូមផ្ទៀងផ្ទាត់រាល់ទិន្នន័យដែលបានបញ្ចូលរួចរបស់អ្នក មុននឹងចុចប៊ូតុង **រក្សាទុក**។ លោកអ្នកមិនអាចកែប្រែទិន្នន័យនេះវិញទេ ។

## 3.2. ការបញ្ចូលទិន្នន័យលើទំរងទី២

បន្ទាប់ពីធ្វើការរក្សាទុកទិន្នន័យនៃទំរង់នីមួយទៅក្នុងប្រព័ន្ធជាស្ថាពរហើយ លោកអ្នកតម្រូវឲ្យបំពេញនូវទំរង់ទីពីរដែលជាទំរង់ ពិពណ៌នាអំពីលទ្ធផលកិច្ចសន្យា និងទី



តាំងនៃគម្រោងក្រុង ស្រុក ខណ្ឌ ជាបន្តដែលមានរូបភាពដូចខាងក្រោម៖

ទិន្នន័យ និងលក្ខខណ្ឌដែលត្រូវបញ្ចូលនៅក្នុងទំរងទីពីមានដូចជា៖

- ការពិពណ៌នាដអំពីឯកសារពិគ្រោះថ្លៃ     ឧ. ផ្គត់ផ្គង់សម្ភារៈជួយជនរងគ្រោះ
- ទីកន្លែងនៃគម្រោង កន្លែងណាមួយនៃគម្រោង ឧ. សាលាក្រុងប៉ៃលិន




ក្រោយពីបានបញ្ចូលទិន្នន័យទៅក្នុងទំរង់ទី១រួចរាល់    ដើម្បីរក្សាទុកទិន្នន័យទាំងនោះទៅក្នុងប្រព័ន្ធ លោកអ្នកត្រូវចុចប៊ូតុង រក្សាទុក ដូចដែលបានបង្ហាញក្នុងរូបខាងក្រោម ៖




បន្ទាប់ពីធ្វើការ រក្សាទុកពីទិន្នន័យនៃគម្រោងទី១ រួចរាល់ហើយលោកអ្នកអាចបន្តបញ្ចូលទិន្នន័យនៃគម្រោងទី២ ទី៣ (មិនកំណត់)នៅលើទំរង់ដដែលជាបន្តបន្ទាប់។

**ចំណាំ៖** សូមផ្ទៀងផ្ទាត់រាល់ទិន្នន័យដែលបានបញ្ចូលរួចរបស់អ្នក មុននឹងចុចប៊ូតុង **រក្សាទុក**។លោកអ្នកមិនអាចកែប្រែទិន្នន័យនេះវិញទេ។

បញ្ជាក់៖ បន្ទាប់ពីបានរក្សាទុកទិន្នន័យនៃគម្រោងក្នុងប្រព័ន្ធរួចរាល់ ត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយស្វ័យប្រវត្ត អាស្រ័យហេតុនេះអ្នកទស្សនាគេហទំព័រប្រគ្រប់គ្រងដេញថ្លៃគម្រោង ក្រុង ស្រុក ខណ្ឌ អាចមានលទ្ធិភាពមើលទិន្នន័យនៃគម្រោងទាំងនោះបានភ្លាមៗ។

## 4. ការបដិសេធប្រកាស

ដើម្បីធ្វើការបដិសេធប្រកាសបាន លោកអ្នកត្រូវចូលទៅក្នុង បញ្ជីនៃសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃតាម ក្រុង ស្រុក ខណ្ឌ ដោយចុចលើប៊ូតុង បញ្ជីប្រកាស ដូចរូបខាងក្រោម៖



បញ្ជីប្រកាស

| # | ក្រុង / ស្រុក / ខ័ណ្ឌ | ចំនួនគម្រោង | កាលបរិច្ឆេទចេញផ្សាយ | ថ្ងៃបើកសំណើរ | ទីកន្លែងដេញថ្លៃ | |
|---|---|---|---|---|---|---|
| 1 | ប៉ៃលិន | 2 | 10/2/2017 11:48:49 AM | 10/11/2017 11:45:00 AM | សាលាស្រុកសាលាក្រៅ | ⊘ |

© 2017 - DMF Application, Developed by Chetra Yeang(IT Officer)

ដូចរូបដែលបានបង្ហាញខានលើ លោកអ្នកនឹងឃើញរាល់ប្រកាសដែលលោកអ្នកបានធ្វើការបង្កើតនឹងផ្សព្វផ្សាយពីមុនមក។ ក្នុងនោះដែរ លោកអ្នកនឹងឃើញនូវទិន្នន័យខ្វះៗតែប៉ុណ្ណោះ ប្រសិនបើលោកអ្នកចង់មើលនូវទិន្នន័យទាំងស្រុង នៃប្រកាសណាមួយនោះលោកអ្នកគ្រាន់តែចុចលើ ឈ្មោះក្រុង ស្រុក ខណ្ឌ តែប៉ុណ្ណោះ។

ជាមួយគ្នានេះដែរយើងនឹងឃើញថាមានប៊ូតុងព៌ណក្រហមមួយ នៅខានស្តាំបង្អស់នៃប្រកាសនីមួយៗ។ប៊ូតុងព៌ណក្រហមនេះហើយ គឺជាប៊ូតុង សម្រាប់ឲ្យលោកអ្នកធ្វើការ បដិសេធ។

ប្រសិនបើលោកអ្នកមានបំណងធ្វើការបដិសេធប្រកាសទៅលើ ក្រុង ស្រុក ខណ្ឌ លោកអ្នកគ្រប់តែចុចលើប៊ូតុងក្រហមដែល នៅខាងស្តាំនៃប្រកាសនោះ នោះប្រព័ន្ធនឹងបង្ហាញលោកអ្នកពីទំរងដើម្បីបដិសេធប្រកាសដូចរូបខាងក្រោម៖




ទិន្នន័យដែលលោកអ្នកត្រូវបញ្ចូល ដើម្បីធ្វើការបដិសេធគម្រោងមានដូចជា លេខរបស់លិខិតបដិសេធ ឯកភាពដោយ កាលបរិច្ឆេទ និងបញ្ចូលលិខិត លោកអ្នកត្រូវជ្រើសរើសគម្រោងណាមួយដែលលោកអ្នកចង់ធ្វើការបដិសេធ។

ប្រសិនបើលោកអ្នកមិនចង់ធ្វើការបដិសេធគម្រោងណាមួយទេ ហើយលោកអ្នកចង់ត្រឡប់ក្រោងសូមចុចប៊ូតុង ត្រឡប់ក្រោយ។

ប្រសិនបើលោកអ្នកចង់ធ្វើការ បដិសេធគម្រោងណាមួយ លោកអ្នកគ្រាន់តែចុចទៅលើប្រអប់ជ្រើសរើស ដែលនៅលើគេបង្អស់នោះ។ ប៉ុន្តែប្រសិនបើលោកអ្នកចង់េធ្វើការបដិសេធ លើគម្រោងមួយចំនួនតែប៉ុណ្ណោះលោកអ្នកគ្រាន់តែចុចលើប្រអប់ជ្រើសរើសដែលនៅពីមុខនៃគម្រោងនីមួួយៗដែលលោកអ្នកចង់បដិសេធ។

បន្ទាប់ពីការបញ្ចូលទិន្នន័យទាំងអស់ ព្រមទាំងបានជ្រើសរើសគម្រោងដែលលោកអ្នកចង់បដិសេធរួចហើយលោកអ្នកគ្រាន់តែចុចលើប៊ូតុង បដិសេធ នោះជាការស្រេច។

សូមមើលរូបឧទាហរណ៍



ចំណាំ៖ សូមផ្ទៀងផ្ទាត់រាល់ទិន្នន័យអោយបានច្បាស់ មុននឹងចុចប៊ូតុង បដិសេធ លោកអ្នកមិនអាចកែប្រែទិន្នន័យនេះ ឬលុបចោលបានទេ។

បន្ទាប់ពីធ្វើការបដិសេធប្រកាសជាស្ថាពរហើយ នៅពេលដែលយើងចូលទៅកាន់ទំព័របញ្ជីនៃសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃតាម ក្រុង ស្រុក ខណ្ឌនីមួយៗម្តងទៀត លោកអ្នកនឹងឃើញថានៅក្នុងចន្លោះគម្រោង និងមានលេខពណ៌ក្រហម ស្តីពីចំនួនគម្រោងដែលបានបដិសេធ ដូចរូបខាងក្រោម៖

